ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
ចូល លេខ 319
ថ្ងៃទី 10-07-2017
បញ្ជូន

លេខ ៣៧៥ ប្រក. កសក

# ប្រកាស
# ស្តីពី
# ស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសំបកវេចខ្ចប់ពូជដំណាំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៀរក្សាសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានីខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវស្លាកសញ្ញាព័ត៌មានពូជដំណាំ ដែលត្រូវបង្ហាញនៅលើសំបកវេចខ្ចប់ពូជដំណាំគ្រប់ប្រភេទ ដែលធ្វើអាជីវកម្ម ឬធ្វើចរាចរណ៍លើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅធានានូវព័ត៌មានស្តីពីពូជដំណាំគ្រប់ប្រភេទ ដែលត្រូវបញ្ជាក់នៅលើសំបកវេចខ្ចប់ពូជដំណាំ ដែលធ្វើចរាចរណ៍លើទីផ្សារក្នុងគោលបំណងធ្វើអាជីវកម្ម ឬធ្វើប្រតិបត្តិការក្រៅគោលបំណងអាជីវកម្ម ដើម្បីបង្កើនការយល់ដឹងអំពីព័ត៌មានបច្ចេកទេស និងរបៀបប្រើប្រាស់ពូជដំណាំ បង្កើនភាពប្រុងប្រយ័ត្នចំពោះពូជដំណាំក្លែងគុណភាពឬមានប្រភពមិនស្របច្បាប់ ការពារផលប្រយោជន៍របស់អាជីវករពូជដំណាំ ព្រមទាំងកសិករ និងអ្នកប្រើប្រាស់ពូជដំណាំផ្សេងទៀត នៅក្នុងផលិតកម្មកសិកម្ម។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រភេទពូជដំណាំគ្រប់ប្រភេទ រួមមានប្រភេទពូជដែលមានស្រាប់ និងពូជថ្មីនៃដំណាំ ព្រមទាំងរាល់សកម្មភាពដែលពាក់ព័ន្ធនឹងផលិតកម្មពូជដំណាំគ្រប់ប្រភេទ ក្នុងគោលបំណងឬក្រៅគោលបំណងអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រកាសនេះមិនគ្របដណ្តប់ ចំពោះពូជដំណាំដែលស្ថិតនៅក្រោមរូបភាពប្រើប្រាស់ជាក់លាក់ក្នុងផលិតកម្មកសិកម្មជាលក្ខណៈគ្រួសារ និងមិនធ្វើចរាចរណ៍លើទីផ្សារ។

## ជំពូកទី២

## សំបកវេចខ្ចប់ពូជដំណាំ

### ផ្នែកទី១

### ការតម្រូវស្លាកសញ្ញាព័ត៌មានស្តីពីពូជដំណាំ

**ប្រការ ៤.-**

ពូជដំណាំគ្រប់ប្រភេទ ដែលធ្វើអាជីវកម្មគ្រប់រូបភាព និងធ្វើចរាចរណ៍លើទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវរៀបចំប្រចកក្នុងសំបកវេចខ្ចប់ឬសម្ភារវេចខ្ចប់ ដែលផលិតដោយវត្ថុធាតុធន់នឹងភាពរហែកធ្លុះធ្លាយ ធន់នឹងធាតុអាកាសមិនងាយថយចុះគុណភាព ព្រមទាំងសម្រួលដល់ការដឹកជញ្ជូន ការធ្វើសន្និធិ និងការប្រើប្រាស់។

សំបកវេចខ្ចប់ ពូជដំណាំគ្រប់ប្រភេទ ត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ដែលអាចបោះពុម្ពឬបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់នោះ។

ការវេចខ្ចប់ជាថ្មីនូវពូជដំណាំគ្រប់ប្រភេទ សម្រាប់បម្រើតាមតម្រូវការទីផ្សារ ត្រូវធានាដូចគ្នានូវសំបកវេចខ្ចប់ ដូចបានកំណត់លក្ខខណ្ឌនៅក្នុងប្រកាសនេះ និងត្រូវរក្សាស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ជាចាំបាច់សម្រាប់អ្នកប្រើប្រាស់។

**ប្រការ ៥.-**

ស្លាកសញ្ញាព័ត៌មាន គឺជាបទប្បញ្ញត្តិដែលបានបោះពុម្ពនៅលើសំបកវេចខ្ចប់ពូជដំណាំ ឬបានកំណត់នៅក្នុងបរិយាយប័ណ្ណព័ត៌មានសម្រាប់ប្រភេទពូជដំណាំណាមួយ នៅក្នុងប្រតិបត្តិការផលិតនិងកែច្នៃ ការវេចខ្ចប់ និងការវេចខ្ចប់ជាថ្មី ដើម្បីធានាគុណភាព និងសុវត្ថិភាពនៃពូជដំណាំសម្រាប់អាជីវករនិងអ្នកទិញយកទៅប្រើប្រាស់។

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំនូវគំរូស្លាកសញ្ញាព័ត៌មានពូជដំណាំនោះតាមយថាប្រភេទនីមួយៗ សម្រាប់ការពិនិត្យនិងវាយតម្លៃដោយអគ្គនាយកដ្ឋានកសិកម្ម ស្របតាមការតម្រូវលក្ខខណ្ឌសម្រាប់ស្លាកសញ្ញាព័ត៌មានពូជដំណាំ។

**ប្រការ ៦.-**

ការតម្រូវលក្ខខណ្ឌសម្រាប់ស្លាកសញ្ញាព័ត៌មានពូជដំណាំ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ព័ត៌មាននៅលើស្លាកសញ្ញា ត្រូវតែមានជាភាសាខ្មែរ ងាយអាន ងាយយល់ និងមិនងាយលុប។

២-ស្លាកសញ្ញាព័ត៌មានអាចត្រូវបានរចនាទម្រង់ស្របតាមប្រភេទនិងទំហំសំបកវេចខ្ចប់ និងប្រភេទពូជដំណាំនីមួយៗ ដោយប្រមូលផ្តុំនូវព័ត៌មានសំខាន់ៗ សម្រាប់អ្នកប្រើប្រាស់អានដោយយកចិត្តទុកដាក់ នៅមុនពេលសម្រេចចិត្តទិញពូជដំណាំនោះយកទៅធ្វើអាជីវកម្ម ឬប្រើប្រាស់។

៣-ចំពោះសំបកវេចខ្ចប់ដែលមានទំហំតូច ស្លាកសញ្ញាព័ត៌មានអាចបោះពុម្ពតែព័ត៌មានសំខាន់ៗនៃពូជដំណាំប៉ុណ្ណោះ។ ចំពោះអត្ថបទណែនាំស្តីពីរបៀបប្រើប្រាស់ពូជដំណាំ និងព័ត៌មានផ្សេងទៀតអាចបោះពុម្ពឬរៀបចំឱ្យមានបរិយាយប័ណ្ណព័ត៌មានពូជដំណាំដោយឡែក។

៤-ស្លាកសញ្ញាព័ត៌មានពូជដំណាំដែលត្រូវបោះពុម្ពនៅលើសំបកវេចខ្ចប់ ឬនៅក្នុងបរិយាយប័ណ្ណព័ត៌មានពូជដំណាំត្រូវមានព័ត៌មានអប្បរមា ដូចខាងក្រោម៖

ក-នៅផ្នែកខាងមុខឬផ្នែកសំខាន់នៃសំបកវេចខ្ចប់៖

-ឈ្មោះដំណាំ៖ ឈ្មោះវិទ្យាសាស្ត្រ ឈ្មោះពាណិជ្ជកម្ម ឈ្មោះក្នុងស្រុក

-ប្រភេទពូជ

-ចំណាត់ថ្នាក់

-ពាណិជ្ជសញ្ញា

-លេខវិញ្ញាបនបត្របញ្ជាក់គុណភាព

-អត្រាសំណើម

-អត្រាដំណុះ

-ភាពសុទ្ធនៃពូជដំណាំ

-កាលបរិច្ឆេទផលិតនិងវេចខ្ចប់ និងកាលបរិច្ឆេទផុតសុពលភាព

-ប្រភេទថ្នាំកសិកម្មដែលប្រើសម្រាប់ការពារ

-របៀបប្រើប្រាស់។

ខ-ផ្នែកខាងខ្នងឬផ្នែកបន្ទាប់បន្សំនៃសំបកវេចខ្ចប់៖

-ឈ្មោះ និងអាសយដ្ឋាន ក្រុមហ៊ុន/ប្រទេស ប្រភពដើមផលិត កែច្នៃពូជដំណាំ
-ឈ្មោះ និងអាសយដ្ឋាន ក្រុមហ៊ុន/ប្រទេស នាំចូលនិងចរាចរណ៍លើទីផ្សារ
-លេខឡូត៍
-បរិមាណពូជដំណាំ (ក្រាមឬគីឡូក្រាមឬចំនួន) ។

## ផ្នែកទី២
## រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព

**ប្រការ ៧.-**

អនុញ្ញាតឱ្យបង្កើត និងប្រើប្រាស់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព សម្រាប់បិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ផលិតផលពូជដំណាំដែលអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬចរាចរណ៍លើទីផ្សារ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋានកសិកម្ម ត្រូវគ្រប់គ្រងការប្រើប្រាស់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពដែលត្រូវបិទឬភ្ជាប់លើសំបកវេចខ្ចប់ផលិតផលពូជដំណាំគ្រប់ប្រភេទ ដែលបានត្រួតពិនិត្យគុណភាពរួច និងបានផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំជាធរមាន។

**ប្រការ ៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើអាជីវកម្មផលិតកែច្នៃ ឬពង្រីកពូជដំណាំ និងធ្វើការនាំចូលពូជដំណាំ ត្រូវបានផ្តល់រូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព ដើម្បីបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ផលិតផលពូជដំណាំរបស់ខ្លួននៅមុនពេលអនុញ្ញាតឱ្យធ្វើចរាចរណ៍លើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ផលិតផលពូជដំណាំគ្រប់ប្រភេទ ដែលបានទទួលវិញ្ញាបនបត្របញ្ជាក់គុណភាពស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំត្រូវមានរូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាពបិទឬភ្ជាប់នៅលើសំបកវេចខ្ចប់ជាចាំបាច់ ដើម្បីសម្គាល់នូវផលិតផលពូជដំណាំ ដែលបានត្រួតពិនិត្យគុណភាពរួច និងត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម ឬធ្វើចរាចរណ៍លើទីផ្សារស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**ប្រការ ១០.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលធ្វើអាជីវកម្មឬធ្វើចរាចរណ៍លើទីផ្សារពូជដំណាំគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលខុសត្រូវចំពោះគុណភាពពូជដំណាំរបស់ខ្លួន ដែលដាក់តាំងលក់ឬធ្វើសន្និធិសម្រាប់លក់ ដែលតម្រូវឱ្យមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងត្រូវមានរូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព បិទឬភ្ជាប់

នៅលើសំបកវេចខ្ចប់ពូជដំណាំនោះជាចាំបាច់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងប្រកាសនេះជាធរមាន។

**ប្រការ ១១.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ ដោយអនុលោមតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៣.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី...០៧...ខែ...កក្កដា.....ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-ក្រសួងពាណិជ្ជកម្ម
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ



រូប "ព្រះមេ" ជារូបសញ្ញាសម្គាល់ពូជដំណាំបានបញ្ជាក់គុណភាព